## ព័ត៌មានសំខាន់ៗខាងក្នុង...

តើសហគមន៍ខ្មែរបោះឆ្នោតរបៀបណា?

សូមអានទៅទំព័រទី ០៥



ARTSEMERSON WELCOMES
**BANGSOKOL: A REQUIEM FOR CAMBODIA...**

Please Read Page 10



ដំណើរឆ្ពោះទៅរកលិទ្ធិផ្តាច់ការនៅកម្ពុជា "ភាគ២"......

សូមអានទៅទំព័រទី០៩



ខ្ញុំ......

សូមអានទៅទំព័រទី០៣



សារព័ត៌មាន ខ្មែរផុស ស.រ.អា Free
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធានា មិនលិច បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

# សំណាងផ្ទុះសង្គ្រាមនៅកូរ៉េខាងជើងកើនដល់កំពូល



ពលរដ្ឋកូរ៉េមានការព្រួយបារម្ភពីការផ្ទុះសង្គ្រាម

ខ្មែរផុសស.រ.អា.

ប្រធានាធិបតី គីម យ៉ុងអ៊ុន នៃកូរ៉េខាងជើង មិនខ្វល់នឹងបទបញ្ជាពីបរទេស ក៏បានបញ្ជាឱ្យបាញ់កាំជ្រួចឆ្លងទ្វីបជាការសាកល្បងជាថ្មីម្តងទៀតកាលពីថ្ងៃអង្គារមុន...កាំជ្រួចនោះបានហោះ៥៤នាទី បានឡើង១០ដងខ្ពស់ជាងមុន ហើយបញ្ចប់ដំណើរសំដៅទៅក្បែរប្រទេសជប៉ុន បើទោះជាមានការហាមប្រាមពីប្រទេសមហាអំណាចសេដ្ឋកិច្ច ឬក៏ពីសហរដ្ឋអាមេរិកដែលមានទ័ពនៅក្បែរប្រទេសខ្លួនរួចជាស្រេចនឹងពីអ.ស.ប. ក៏ដោយក្តី។ ចរិកមេដឹកនាំរបបផ្តាច់ការកុម្មុយនីស្តមិនសូវខុសគ្នាទេ គឺមិនខ្វល់ពិសុខទុក្ខប្រជាពលរដ្ឋទេ គឺគិតតែពីអំណាចខ្លួនឯងតែប៉ុណ្ណោះ។

សហរដ្ឋអាមេរិកបានបញ្ជូនភ្លាមៗ នូវយន្តហោះប្រតិកម្មដ៏ទំនើបបំផុតជាច្រើនគ្រឿងទៅកាន់កូរ៉េខាងត្បូង បន្ថែមលើអ្វីដែលមានរួចទៅហើយ -ពីគ្រប់មាត់នៃមេទ័ពអាមេរិកាំង គេនិយាយថា "សំណាងនៃការផ្ទុះសង្គ្រាមកាន់តែខិតខ្ពស់ឡើងហើយ..."លោកប្រធានាធិបតីត្រាមបានដាក់គំនាបសេដ្ឋកិច្ចយ៉ាងតឹងតែងលើកូរ៉េខាងជើង តែព្យុងយ៉ាងនៅតែផ្តើនដាក់ពិភពលោកមកវិញថែមទៀតគ្មានថយ។ លោកប្រធានាធិបតី "ត្រាម"នៅសល់តែជម្រើសយោធាតែប៉ុណ្ណោះ ដែលប្រហែលជាជៀសមិនរួចទៀតផង មិនតែប៉ុណ្ណោះ គេបារម្ភថា"ទ័ពព្យុងយ៉ាងអាចនឹងវាយអាមេរិកមុនទៀតផង ដោយសារគ្រាប់កាំជ្រួចចុងក្រោយនេះ មាន

តទៅទំព័រទី ២០

## "First They Killed My Father"...

Please Read Page 17



CENTURY PHARMACY
937 Gorham Street. Lowell, MA 01852
Phone: 978-455-6554 | Fax: 978-455-9476

ផ្តល់ជូននូវសេវាប្រសើរបំផុត ផ្តោតទៅលើសេចក្តីត្រូវការរបស់អ្នកជម្ងឺដោយផ្ទាល់
-ធ្វើតាមបំណងស្រួលប្រើថ្នាំ នឹងខ្ចប់ក្នុងបំពង់មើលឃើញថ្នាំ

ចែកចាយដោយឥតគិតថ្លៃក្នុងឡូវែល, ឆែមហ្វិត, ទីងប្ស៊ូ, តេសប៊ឺរី, ដគ្រេខិត, ឡូរ៉ិន អាចប្តូរមកទទួលសេវាយើងវិញ យ៉ាងងាយស្រួល
www.centuryrx.net


MRT
MERRIMACK REPERTORY THEATRE
ទស្សនីយភាពសម្តែងនៅរោងមហោស្រព<មៀរីម៉ាករ៉ាទ្បៀ>
KNYUM
ខ្ញុំ
FAMILY: THE TOUGHEST
LANGUAGE TO LEARN
Written and Performed by
Vichet Chum
Directed by
KJ Sanchez
FARLEY | WHITE
INTERESTS
PRODUCTION SPONSOR
HOWL
MEDIA SPONSOR
TICKETS START AT $26
FREE PARKING
JANUARY 10 – FEBRUARY 4
MRT.ORG | 978-654-4678 | 50 E. MERRIMACK ST., LOWELL

# “ខ្ញុំ”

ខ្មែរផុសស.រ.អា.

“ខ្ញុំ”គឺជាចំណងជើងមួយ ជាភាសាខ្មែរ នៃរឿងល្ខោនដែលនឹងផ្ដើមសម្ដែងនាថ្ងៃទី១០មករាដល់៤កុម្ភៈឆ្នាំ២០១៨, នៅរោងមហោស្រព “MRT” -50E Merrimack st.Lowell” ។ គឺជារឿងដែលនិពន្ធនឹងសម្ដែងដោយ វិចិត្រ ជុំ ជាសិល្បៈករវិជ្ជាជីវៈដើមកំណើតខ្មែរ មកពីរដ្ឋ“តិចសាស់” ដឹកនាំដោយនាយកក្រុមល្ខោននេះ ឈ្មោះ “សង់ ស្ទេស -Sanchez” ។ លោកនាយកផ្នែកសិល្បៈនៃសាលមហោស្រព គឺលោក“ស្ទួន ដានញ៉ល” ដែលបានជ្រើសយករឿងរបស់ វិចិត្រ យកមកសម្ដែងសម្រាប់ក្រុងឡូវែល គឺនៅពេលដែលវិចិត្រកំពុងតែធ្វើវិស្សមកាលនៅកម្ពុជាជាលើកដំបូងបង្អស់នាក្រុងព្រះសីហនុ ។

ចម្លែកណាស់ ហេតុអ្វីក៏អ្នកនិពន្ធនឹងជាសិល្បករសម្ដែងតួរម្នាក់បានចាប់យកចំណងជើងយ៉ាងខ្លីបំផុត មកសម្ដែងនៅរោងល្ខោនយ៉ាងធំបំផុត នៅឡូវែលនេះ យ៉ាងដូច្នេះទៅវិញ? យើងបានតាំងសំនួរមួយចំនួនដល់ វិចិត្រ ដើម្បីចង់បានយល់ពីទស្សនិកជនឡើយ ។

វិចិត្រ ជុំ បានសម្ដែងការរំភើបក្នុងចិត្តណាស់ នៅពេលដឹងថា“រឿងរបស់ខ្លួននឹងបានមកសម្ដែងនៅក្នុងទីក្រុងដែលសម្បូរដោយជនជាតិខ្មែររស់នៅ” តែខ្លួនឯងបែរជាថា “និយាយពាក្យខ្ញុំដំបូងឡើយ មានការពិបាកណាស់ ដោយអានមិនត្រូវ ខ្ញុំខំប្រឹងរៀនធ្វើការផងរៀននិយាយខ្មែរផង ដើម្បីទៅឱ្យស្គាល់ស្រុកខ្មែរ ពីព្រោះខ្ញុំខ្លាចស្រុកខ្មែរ ខ្ញុំខ្លាចគេស្អាប់ខ្ញុំមិនបាន, ខ្ញុំតែងតែចង់ដឹង ហើយសួរទៅឪពុកខ្ញុំ ដែលខ្លួនគាត់ជាជនភៀសខ្លួន ឯខ្ញុំកើតនៅទីនេះ តែខ្ញុំក៏មិនដែលបានចម្លើយដែលខ្ញុំអាចយល់បានពីឪពុកខ្ញុំនោះវិញឡើយ ខ្ញុំតែងសន្ទត់ថា “បានយល់នូវរឿងរ៉ាវដែលខ្ញុំមិនយល់” នោះជារៀងរហូតដល់ក្លាយជាធម្មតាទៅវិញ...” សំនួរដែលគ្មានចម្លើយបានក្លាយទៅជា “ខ្ញុំ” ដែលមិនច្បាស់ថា ជាសំនួរឬក៏ជាចម្លើយ ថាខ្ញុំជានរណា? ឪពុកម្ដាយខ្ញុំមកពីណា? តើអ្នកឯទៀតដូចខ្ញុំដែរឬទេ? ការស្វែងរកនូវអត្តសញ្ញាណដ៏ជ្រាលជ្រៅរបស់វិចិត្រក៏បានក្លាយជាអត្ថបទនិពន្ធដ៏សំខាន់ជាពិសេសមួយដែលធ្វើឱ្យនាយករោងមហោស្រពចាប់អារម្មជាខ្លាំង ហើយក៏ចាប់យកមកឱ្យសម្ដែងឱ្យបញ្ចេញនូវអ្វីដែលជម្រៅរបស់ វិចិត្រ ជាយុវជនដើមកំណើតជាគ្រួសារអ្នកភៀសខ្លួន មកលាតត្រដាងតាមបៀបវិធីសាស្ត្រជាសិល្បករវិជ្ជាជីវៈវិញម្ដង ។

ក្រុមអ្នកឯកទេស ក៏បានគាំទ្រការតស៊ូ ខាងស្មារតីដើម្បីរុករកជម្រៅ“ខ្ញុំ”របស់ វិចិត្រ រហូតដល់បានចេញជារូបរាងបង្ហាញមកក្រៅជាទស្សនីយភាពបាន... ដែលការពិតទៅការរុករកនេះ គឺជាការតស៊ូរបស់គ្រួសារ វិចិត្រ តាំងពី២០ឆ្នាំមុនមកជាកង្វល់ក្នុងគ្រួសារខ្លួន ហើយមិនដែលមានចម្លើយតបវិញទេ មកទល់ពេលនេះ។ វិចិត្រអាចជាអ្នក








ជម្រៅនៃសាច់រឿងរបស់ជនជាតិដ៏តិចបំផុតដែលនិពន្ធរឿងសម្រាប់សម្ដែងជាសាធារណៈ តើ“ខ្ញុំ” វាជាអំនួតជាអំណាច ស្អីទៅ“ខ្ញុំ”នោះ... តែដំបូងបង្អស់ជាខ្មែរម្នាក់ ទោះជារឿងអ្វីក៏ដោយមានមោទនភាពណាស់ដែលភាសារបស់ខ្លួន បានផុសឡើងយ៉ាងសាមញ្ញបំផុត នៅពីមុខរោងមហោស្រពដែលមហាជនចម្រុះសាសន៍ តែងតែទិញសំបុត្រចូលមើលកកកុញ ដោយសារយកតែជម្រើសស្នាដៃសិល្បៈដ៏កំពូលៗ យកមកបង្ហាញនៅទីកន្លែងដែលធ្លាប់តែល្បីល្បាញ ដូច្នេះមិនសូវដែលខុសចិត្ត



ហើយ ។ នៅរដ្ឋតិចសាស វិចិត្រ មានបងស្រីជីដូនមួយឈ្មោះសុជាតា បានបញ្ចេញខ្សែភាពយន្តមួយឈ្មោះ“ទារកនាថ្ងៃចូលឆ្នាំថ្មី - New year Baby” ដែលជាលទ្ធផលនៃការស្វែករកច្រើនឆ្នាំ នូវអត្តសញ្ញាណរបស់កុមារម្នាក់ក្នុងគ្រួសារជនភៀសខ្លួនមួយ, ដោយសារនាងចង់ដឹងថា“តើគ្រួសារនាងមកពីណា? ហេតុអ្វីក៏នាងមិនអាចដឹងអ្វីបន្តិចសោះពីក្រុមគ្រួសារនាង?”, ហើយសំនួរដូចគ្នានេះគឺអាចជាសំនួរនៃយុវជនជាច្រើន ដែលបានបង្កើតបន្ត“អំណោយនៃគ្រួសារ”ក្នុងកំរិតមួយទៀត ដែលទាល់តែនាដករ គឺជាជនភៀសខ្លួនផង នឹងជាយុវជនផង ហើយជាម្ចាស់នៃរឿងថែមទៀត ទើបបញ្ជូនទស្សិយភាពឱ្យដល់កំរិតខ្ពស់បំផុតបាន។

លោក វិចិត្រ ជុំ មានសញ្ញាប័ត្រអនុបណ្ឌិតខាងសម្ដែងសិល្បៈចេញពីមហាវិទ្យាល័យសិល្បៈនៅរដ្ឋ“រ៉ូដអាយឡិន”, សព្វថ្ងៃរស់នៅប្រកបមុខរបរជាសិល្បៈករវិជ្ជាជីវៈ នៅញូយ៉ក។

# ដំណឹងអាសន្នពីអតីតឃុំសង្កាត់កម្ពុជា

ដំណឹងប្រភពឯករាជ្យបានចេញមកក្រៅ "កាន់តែក្រខ្សត់" រីឯដំណឹងបន្តិចបន្តួចដែលទទួលបាន "មិនល្អសោះ"សម្រាប់សមាជិកគណបក្សប្រឆាំង"ដែលស្មោះត្រង់នឹងគណបក្សសង្គ្រោះជាតិ" ។

អ្នកភៀសខ្លួនដោយសារការគៀបសង្កត់របស់អាជ្ញាធរ បានកើនឡើងដោយសារមានការ



សកម្មជនឃុំបានទទួលជំនួយពីសប្បុរសជន

គេចខ្លួនពីកន្លែងដែលខ្លួនរស់នៅទៅនៅកន្លែងដ៏ទៃដើម្បីលាក់ខ្លួនមួយរយៈ -ខ្លះរត់ទៅដល់ប្រទេសថៃទៅប្រជ្រៀតគ្នារស់នៅបណ្តោះអាសន្នជាមួយមិត្តភ័ក្រ្ត ឬអ្នកដែលធ្លាប់ស្គាល់បន្តរគ្នា ។ អ្នកដែលចេញមកប្រទេសថៃបាន និយាយថា "ការធ្វើលិខិតឆ្លងដែលនៅតែបន្តរធ្វើបាននៅឯក្រសួងមហាផ្ទៃក្នុងតម្លៃ១១០ដុល្លា សម្រាប់ឆ្លងដែននៅច្រកព្រំប្រទល់ ក៏ប៉ុន្តែដោយសភាពការតឹងតែងនៅកម្ពុជាគេហាក់ដូចជាឃើញថា"មានការឃោគយល់គ្នានាគ្រាក្រមិនចាំបាច់មានលិខិតឆ្លងដែនក៏អាចរកអ្នកជូនឆ្លងមកបានដែរ" ។

សមាគមមូលនិធិឃុំសង្កាត់គំរូកម្ពុជា ហៅថា ASALEC បានបញ្ជូនជំនួយជាប្រាក់៥០ដុល្លាម្នាក់ទៅដល់ដៃមេឃុំរងគ្រោះនៅបាត់តំបងចំនួន៥នាក់រួចហើយ នឹងបន្តររុករកអ្នករងគ្រោះផ្សេងទៀតដែលកំពុងគេចខ្លួនក្នុងប្រទេស ។ នៅប្រទេសថៃមានជុំវិបណ្តោះអាសន្នមួយមានគ្នាប្រមាណជិត៣០០នាក់ហើយ ដែលខាងឡូវែលត្រៀមនឹងទៅជួយ, ខ្លះក៏មានលិខិតពីស្នងការអ.ស.ប.ខាងជនភៀសខ្លួន ខ្លះក៏គ្មានតែកំពុងប្រឈមមុខនឹងការខ្វះខាតយ៉ាងដំណំ ។

ចំពោះអ្នកដែលមិនបានគេចខ្លួន មិនមានធ្វើសកម្មភាពអ្វីដែលនាំឱ្យមានការចាប់ខ្លួនទេ ខ្លះត្រឡប់ទៅប្រកបមុខរបរដែលធ្លាប់ធ្វើពីមុនមកដូចជានាង"រ៉ូស្វែត"បានចេញពីសង្កាត់អូចារទៅប្រកបមុខរបរលក់ដូរម្ហូបចំណីដែលនាងបានបោះបង់ចោលដើម្បីទៅធ្វើនយោបាយលោក ប៉ុល ហម ឃើញបង្ហោះរូបថតថាទៅកាប់ដូងលក់ តែច្រើនគ្នាបានឱ្យដំណឹងថា"មានការឃ្លាំមើលសកម្មភាពជាប្រចាំដែរ មិនអាចធ្វើការប្រជុំគ្នា៣-៤នាក់បានទេ ។

សមាគមនេះកំពុងបង្កើតបណ្តាញស្របច្បាប់រដ្ឋម៉ាសាឈូសិត៥០១C3 រកធនធានស្ម័គ្រចិត្តនៅ "ឡូវែល"ទូរស័ព្ទ ពិន សំខុន (978)942 1641 នៅ"យូធិកា-ញូយ៉ក"ទូរស័ព្ទ សូផល រៀម (315) 570 0828 ដើម្បីទៅជួយបងប្អូនខ្មែរដែលផ្តើមរងគ្រោះសាជាថ្មី រហូតដល់សានគ្រាននាពេលឆាប់ៗខាងមុខនេះ ។

សូមលោកអ្នកផ្ញើរជំនួយមកទីស្នាក់ការ ASALEC - 26 Lincoln St. #1 Lowell, MA 01852 សមាគមសូមថ្លែងអំណរគុណទុកជាមុន ។ ជំនួយលោកអ្នកអាចកាត់បន្ថយ"តាក់"លោកអ្នកបាន ។



# តើសហគមន៍ខ្មែរបោះឆ្នោតរបៀបណា?

ឡូវែល :

ខ្មែរយើងតែងតែនិយាយថា "ទៅបោះឆ្នោតធ្វើអ្វី បើទោះជាទៅក៏នឹងបានលទ្ធផលនៅតែមិនដូចចិត្តតែដដែលនោះ!" ខ្លះទៀតក៏បន្ថែមថា "រវល់ខ្លាំងណាស់ បើអត់ខ្ញុំម្នាក់ក៏មិនធ្វើឱ្យខូចលទ្ធផលដែរ!" ខ្លះទៀតនិយាយដែរថា "ខ្ញុំមិនចង់ធ្វើនយោបាយទេ!"... គំនិតទាំងឡាយនេះ សុទ្ធតែយើងនាំយកមកពីប្រទេសយើងទាំងអស់, មកដល់ទីនេះហើយ គឺសហរដ្ឋអាមេរិកជាប្រទេសនាំមុខគេខាងប្រជាធិបតេយ្យគំនិតចាស់គឺរលពេកហើយ គួរតែបោះបង់ចោល! ចាប់យកវាស្នាថ្មីនៃប្រទេសដែលគេហៅថា "ប្រទេសដែលផ្តល់ឱកាសឱ្យយើងងើបរួច"... ការបោះឆ្នោត គឺជាការចូលរួមកសាងសង្គមដែលគ្រួសារយើងរស់នៅឱ្យសង្គមនោះផ្តល់ឱកា សមកឱ្យយើង ដើម្បីឱ្យយើងរុងរឿងបាន។ បើទុកតែរបៀបនេះតទៅទៀត ជាលទ្ធផលនៃជំនឿចាស់របៀបនេះ ខ្មែរយើងបានចេញទៅបោះឆ្នោតបញ្ចេញមតិ កាលពីថ្ងៃទី៧ វិច្ឆិកា មិនបានដល់ ២០%ទេ សាសន៍ដ៏ទៃនៅតែមើលបំណាំយើង ហើយដឹកច្រមុះយើងបន្តរទៅទៀត។

កាលពីលេខមុន ខ្ញុំបាននិយាយថាឃុំ "បែលវីធៀ"នៃក្រុងឡូវែល ជាអ្នកដឹកនាំនយោបាយនៃឡូវែលទាំងមូល តើគេធ្វើយ៉ាងណាបានជាម្នាក់ៗមានឆ្នោតមួយសន្លឹកដូចយើងដែរ ស្រាប់តែដឹកមុខឃុំទាំង៧នាក្រុងទាំងមូលបាន? សូមលោកអ្នកមើលលទ្ធផលនៃការបោះឆ្នោត តាមរូបភាពដែលជូនជាប់ជាមួយនេះ...

ក្នុងរូបភាពនោះ យើងឃើញតំបន់ "បែលវីឌៀ" តែមួយមានសមាជិកក្រុមប្រឹក្សាក្រុង"ជាប់ឆ្នោតដល់ទៅ៥រូប" ហើយនៅសល់អាសនៈ៤ទៀតដែលត្រូវចែកឱ្យដល់៦តំបន់ នេះដោយសារតែតំបន់ទាំង៦នោះ មានអ្នកចេញទៅបោះឆ្នោតពី ៨% -២០% ប្រឈមមុខនឹង"បែលវីឌៀ"តែមួយដែលចេញទៅបោះឆ្នោតដល់ទៅ៥៨%, បានន័យថាៈ សេចក្តីសម្រេចនានា នៅឆ្នាំ២០១៨-១៩ ដែលចេញពីសាលាក្រុងឡូវែល គឺមតិភាគច្រើននឹងបានទៅជាសម្បត្តិក្រុម "បែលវីឌៀទាំងអស់ ។



-ពណ៌ក្រហមជ្រើសរើស ខលី តែចាញ់ពណ៌ខៀវ តូចជាង ជ្រើសរើសដោនថោន
-តំបន់បែលវេឌៀតែមួយតូច ឈ្នះបានតំណាងដល់ទៅ៥រូប ក្នុងចំណោម៩រូប




បើខ្មែរចង់ នៅឡូវែលនេះយើងអាចប្តូរចរន្ត "គេដឹកច្រមុះ" នេះបានសហគមន៍ខ្មែរចុះឈ្មោះបោះឆ្នោតជាង១ម៉ឺននាក់ នៅជុំគ្នា និយាយភាសាតែមួយមានទំនាក់ទំនងគំនិតល្អៗជាមួយគ្នាបាន មិនពិបាកនឹងធ្វើឱ្យមានតំណាងរបស់ខ្លួនប្រចាំឡូវែលនេះទេ "បែលវីឌៀ" ក៏មិនអាចទប់ចរន្តខ្មែរនេះជាប់ដែរ តែមានលក្ខខណ្ឌមួយដែលត្រូវបំពេញគឺត្រូវចេញទៅបោះឆ្នោតឱ្យបានតែ "៥ពាន់នាក់" សោះនឹងបានតំណាងខ្មែរប៉ុន្មាននាក់ក៏បានដែរ ចង់បានសាសន៍អីក៏បាន...ឱ្យតែគេមានចិត្តស្រឡាញ់ខ្មែរ ហើយរួមរស់ប្រកបដោយមិត្តស្នេហភាពគ្នា។ មកទល់ពេលនេះ លោក "វតនីយ អេលីយ៉ុត - លោកស្រី រីដា មែសើ- លោក ដាន់ រូក - លោក ជិម ឡេរី - លោក កូរី បាឡិនជើ... សុទ្ធតែធ្លាប់បង្ហាញពីភក្តីភាពចំពោះសហគមន៍ខ្មែរយើងយ៉ាងជ្រាលជ្រៅ រួចមកហើយដែរ។ គ្រាន់តែខ្ញុំនិយាយប៉ុណ្ណេះ លោកអ្នកអាចប៉ាន់ប្រមាណថា "សហគមន៍ខ្មែរអាចមានកម្លាំងខ្លាំងបុណ្ណារួចទៅហើយ" គឺឆ្នោត៥ពាន់សន្លឹក ដែលយើងអាចគូសយកបេក្ខជន ដល់ទៅ៩នាក់ គឺវាក្លាយជាសន្លឹកឆ្នោតជិត៥-ម៉ឺនសម្លេងនៃសហគមន៍ខ្មែរគិតទៅមើល តើយើងនឹងអាចមានតំណាងប៉ុន្មានរូប ដែលបំរើសហគមន៍យើងនៅសាលាក្រុង?

គេថា "សហគមន៍ខ្មែរចេះតែបែកគ្នា" ប្រមូលសម្លេង៥ពាន់នាក់មិនបានទេឬ? វាជាការពិតនៃស្ថានភាពសព្វថ្ងៃនេះ, បើយើងជ្រើសយកអ្នកដែលចូលចិត្តតែបែងចែកគ្នា ជាក្រុមជាបក្ខពួកឱ្យទៅប្រមូលគ្នានោះ អ្នកនឹងមិនអាចបានក្រុមដែលមូលតែមួយបានទេ, ប៉ុន្តែគេក៏អាចរកមនុស្សដែលមានឧត្តមគតិនិយមដឹងត្រូវខុសមិនប្រកាន់ "គ្នាគេគ្នាអញ", ឱ្យមកជាអ្នកប្រមូលផ្តុំគ្នាលើកបញ្ហានឹងដំណោះស្រាយរួម នោះទើបសាមក្គីភាពវាអាចកើតឡើងបាន។

ម្យ៉ាងទៀត នៅសហគមន៍ខ្មែរយើងមានការអប់រំនយោបាយបែបអាមេរិកាំងនេះតិចតួចរីឯមនុស្សជំនាន់ថ្មីរៀនសូត្របានច្រើន តែដឹងពីសង្គមខ្មែរនឹងវត្ថុបំណងសហគមន៍ "អតីតជនភៀសខ្លួន" តែចូលជាថ្នាក់ដឹកនាំមិនចុះសម្រុងគ្នានឹងជំនាន់មុនទេ ទោះជាមានចំនួនកាន់តែច្រើនគួរសមមែនក៏ដោយ ។ ហេតុនេះ "ចាស់ទុំ" នៃសហគមន៍យើងត្រូវចេះដើរតួរជា "ព្រឹទ្ធាចារ្យ" អ្នកមានចិត្តសណ្តោសចូលចិត្តប្រមែរប្រមូលមនុស្សគ្រប់ជំនាន់ឱ្យមកសម្តែងការចេះដឹងរបស់ខ្លួន សម្តែងការចង់បំរើសហគមន៍របស់ខ្លួន ពេលនោះទើបយើងអាចឃើញថា "សហគមន៍យើងក៏មានបេក្ខជនចំណាន់ៗច្រើនណាស់នឹងគេដែរ អាចជាសេចក្តីសង្ឃឹមរបស់ព្រឹទ្ធាចារ្យយើងទៅអនាគតបាន ។ ដោយ ពិន សំខុន

# ទំនាក់ទំនងការអប់រំរវាងសាលាមីុដូលស៊ិច ខាមញូនីធី ខលលិចនិងកម្ពុជា

ដោយខ្មែរផុស ស.រ.អា

ឡូវែល- សាលាមីុដូលស៊ិច ខាមញូនីធី ខលលិចគឺជាសាលាឯកជនដ៏ធំមួយដែលមានទីតាំងក្រុងឡូវែល ហើយបានបណ្តុះបណ្តាលធនធានមនុស្សចំរុះជាតិសាសន៍រាប់មុឺននាក់ជារៀងរាល់ឆ្នាំ។ អ្វីដែលគួរឱ្យកត់សម្គាល់នេះគឺថាក្រៅពីជាទីកន្លែងក្នុងការផ្តល់ចំណេះដឹង សាលាមីុដូលស៊ិច ក៏បានធ្វើការងារជាច្រើនជាពិសេសទៅលើផ្នែកអប់រំជាមួយសហគមន៍ខ្មែរនៅអាមេរិក និងនៅប្រទេសកម្ពុជាផងដែរ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សាលាមីុដូលស៊ិច បានទទួលថវិការមួយចំនួនពីក្រសួងអប់រំរបស់រដ្ឋនិងមូលនិធិជាតិដើម្បីសិល្បៈ (National Endowment for the Arts) សម្រាប់យកមកធ្វើការអនុវត្តន៍គម្រោងការងារជាច្រើនជាមួយកម្ពុជា។ ដោយក្នុងនោះ គម្រោងថវិការសរុបចំនួនជាង២០មុឺនដុល្លារ ដែលសាលាមីុដូលស៊ិចបានទទួលពីក្រសួងអប់រំអាមេរិក សម្រាប់



គម្រោងបីដោយឡែកៗពីគ្នា។

ដោយគម្រោងទី១ មានឈ្មោះថា ហ្វូលប្រាយហាយ មានថវិការចំនួនប្រហែល ៩ មុឺនដុល្លារកាលពីឆ្នាំ២០១០ ដោយខាងសាលាបានធ្វើការសហការជាមួយមហាវិទ្យាល័យបញ្ញាសាស្ត្រ ដើម្បីចូលរួមក្នុងសកម្មភាពសិក្សារស្រាវជ្រាវរួមគ្នានិងបង្កើតការផ្លាស់ប្តូរផ្នែកអប់រំនិងវប្បធម៌រវាងប្រទេសទាំងពីរ ។



ការផ្តល់អំណោយវីយ៉ូឡុងដល់តំណាងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈកម្ពុជា

នៅឆ្នាំ ២០១៣ សាលាបានទទួលថវិការចំនួនជាង៤មុឺនដុល្លារពីមូលនិធិជាតិដើម្បីសិល្បៈ សម្រាប់គាំទ្រដល់ការអភិរក្ស, ការយល់ដឹង, និងការកោតសរសើរចំពោះសិល្បៈស្ទូនរូបរបស់កម្ពុជាដែលជិតបាត់បង់ និងដើម្បីលើកទឹកចិត្តដល់អ្នកជំនាន់ក្រោយក្នុងការចូលរួមចាប់ជំនាញផ្នែកស្ទូនរូបកម្ពុជាផងដែរ។

គម្រោងទី៣ មានឈ្មោះថា បេតិកភណ្ឌវប្បធម៌របស់កម្ពុជានៅក្នុងពិភពលោកសម័យទំនើប។ សាលាក៏បានចំណាយទឹកប្រាក់ជាង៩មុឺនដុល្លារដែលបានមកពីក្រសួងអប់រំនៅឆ្នាំ២០១៥ សម្រាប់ឱ្យអ្នកចូលរួមក្នុងគម្រោងទទួលបានចំណេះដឹង និងស្វែងយល់ពីទំរង់សិល្បៈបុរាណ និងសម័យរបស់ប្រទេសកម្ពុជាដើម្បីយកបទពិសោធន៍ទាំងនេះបង្កើតជាសកម្មភាពអប់រំលក្ខណៈបែបសិល្បៈបុរាណដល់សិស្សានុសិស្សថ្នាក់បឋមសិក្សា,វិទ្យាល័យ និងមហាវិទ្យាល័យ។

ក្រៅពីគម្រោងទាំងនេះ សាលាមីុដូលស៊ិច កាលពីខែតុលា ឆ្នាំ២០១៥ បានរៀបចំកម្មវិធីអបអរសាទរដល់លោកយ៉ារី លីវ៉ាន់ ដែលបង្រៀននៅសាលាមីុដូលស៊ិចដែលត្រូវបានទទួលរង្វាន់ NEANational Heritage Fellowship ប្រចាំឆ្នាំ ២០១៥។ ជាងនោះទៅទៀត សាលាក៏បានចូលរួមចំណែកក្នុងផ្តល់អំណោយជាវីយ៉ូឡុងដែលពិសេសៗកាបូនដល់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈរបស់កម្ពុជាផងដែរ កាលពីខែមិថុនា ឆ្នាំ ២០១៦ តាមរយៈយុទ្ធនាការរៃអង្គាសប្រាក់ដែលមានឈ្មោះថា ស្ពឹងខាមបូឌា។

តាមរយៈសកម្មភាពសហប្រតិបត្តិការទាំងនេះ តទៅទំព័រទី ០៧

វាបានឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ និងការគាំទ្ររបស់សាលាដូលស៊ិច ខាមញូនីធីខលលិចដល់កម្ពុជា ព្រមទាំងបង្ហញពីទំទាក់ទំនងយ៉ាងជិតស្និតលើផ្នែកអប់រំរវាងសាលានិងពលរដ្ឋខ្មែរទាំងនៅអាមេរិក និងកម្ពុជា។

គួបញ្ជាក់ថា សាលាមីុដូលស៊ិច ខាមញូនីធីខលលិចដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការផ្នែកធនធានមនុស្សការសិក្សារនិងការអប់រំសម្រាប់សហគមន៍នៅក្នុងស្រុក និងអន្តរ-ជាតិ។ សាលាមីុដូលស៊ិច ដែលជាសាលាធំបំផុតមួយក្នុងចំណោមសាលាធំៗជាច្រើននៅក្នុងរដ្ឋបានអប់រំសិស្សានុសិស្សជាង១៣,០០០នាក់ជារៀងរាល់ឆ្នាំ តាមរយៈការបង្រៀនដោយផ្ទាល់ និងតាមអនឡាញ។


## ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៏
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**



Your're cordially invited to the

**Christmas PARTY**

a Fundrasier to help benefiting the Southeast Asian Scholarship Fund

**Thursday, December 28, 2017**
**5:30 - 8:00 pm**
Art League of Lowell
307 Market Street. Lowell, MA

Cocktails and Hors d'Ueuvres will be served.

All donations will proceed toward the Southeast Asian Scholarship's Fund.

**Sponsored by** KhmerPost USA

For more information,
contact Soben Pin at: sobenpin@khmerpost.us
**978-677-7163**

# ព្រឹទ្ធសភាបារាំងទាមទារអោយសមាជិកប្រទេសជាហត្ថលេខីនៃកិច្ច ព្រមព្រៀងទីក្រុងប៉ារីស កោះប្រជុំដើម្បីចាត់ការកម្ពុជាជាបន្ទាន់

ប្រទេសបារាំង :

សមាជិកព្រឹទ្ធសភានៃប្រទេសបារាំងមួយរូប មកពីគណបក្ស"En Marche!" លោក អង់ដ្រេ ហ្គាតូឡាំង (André Gattolin) បានចេញលិខិតប្រកាសព័ត៌មានបញ្ជាក់ពីការទាមទារអោយប្រទេសជាតិហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស កោះប្រជុំជាបន្ទាន់ដើម្បីចាត់ការមកលើប្រទេសកម្ពុជា ។ នេះបើយោងតាមការដកស្រង់សម្តីមកចុះផ្សាយដោយសារព័ត៌មានមនោរម្យកាលពីថ្ងៃម្សិលមិញនេះ ។

សារព័ត៌មានដដែលនេះក៏បានបន្តដកស្រង់សម្តីរបស់លោក អង់ដ្រេ ហ្គាតូឡាំង (André Gattolin) មកចុះផ្សាយអោយដឹងទៀតថា លោក អង់ដ្រេ ហ្គាតូឡាំង បានថ្លែងបន្តក្នុងកិច្ចសម្ភាសន៍ជាមួយវិទ្យុ «RFI» "ប្រទេសបារាំង ក៏ដូចជាសហភាពអ៊ឺរ៉ុប ត្រូវកោះប្រជុំឱ្យបានលឿនតាមតែអាចធ្វើទៅបាននូវភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩១ ដើម្បីសម្លឹងរកមើលការចាត់វិធានការនៅចំពោះការងាកទៅរករបបផ្តាច់ការមួយនៅកម្ពុជា។

ក្នុងសេចក្តីប្រកាសព័ត៌មានជាភាសាបារាំង ដែលត្រូវបានសារព័ត៌មានមនោរម្យបកប្រែមកចុះផ្សាយបានអោយដឹងថាសមាជិកព្រឹទ្ធសភារូបនេះ



ក៏បានលើកឡើងផងដែរថា ការហាមឃាត់ក្រុមអ្នកនយោបាយប្រឆាំងនៅក្នុងប្រទេសកម្ពុជា មានន័យថា "បន្ទាត់ក្រហម"មួយ ទើបនឹងត្រូវបានលោតរំលងដោយរដ្ឋាភិបាលកម្ពុជា។ ហើយបរិយាកាសនយោបាយក្នុងរយៈពេលចុងក្រោយបាន"ដើរផ្ទុយទៅនឹងដំណើរការនៃលទ្ធិប្រជាធិបតេយ្យដែលកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១បានកំណត់សម្រាប់ប្រទេសកម្ពុជា"។

សមាជិកព្រឹទ្ធសភារូបនេះ ដែលជាអនុប្រធាននៃគណៈកម្មការនៃកិច្ចការអ៊ឺរ៉ុប (របស់ព្រឹទ្ធសភាបារាំង) និងជាអនុប្រធាននៃក្រុមសមាជិកព្រឹទ្ធសភាជាមិត្ត បារាំង-កម្ពុជា បានបន្តបរិហារសាលក្រមរបស់តុលាការកំពូលកម្ពុជាថា មានលក្ខណៈ "ដ៏អាស្រូវ" និង"ដ៏អយុត្តិធម៌" ដែលមិនគួរឱ្យយល់បាន។ នេះបើយោងតាមការចុះផ្សាយដោយសារព័ត៌មានមនោរម្យនៅថ្ងៃអង្គារនេះ ។

ថ្លែងនៅក្នុងកិច្ចសម្ភាសមួយជាមួយវិទ្យុសម្លេងបារាំងអន្តរជាតិ «RFI» ផ្សាយជាភាសាបារាំង លោក ហ្គាតូឡាំង បានបញ្ជាក់ថា ប្រទេសបារាំងរួមនឹងសហភាពអ៊ឺរ៉ុបនឹងចាត់វិធានការដ៏ខ្លាំងមួយ ដើម្បីដាក់ទណ្ឌកម្មទៅលើរបបដឹកនាំក្រុងភ្នំពេញ ក្នុងនោះរាប់បញ្ចូលទាំងការលប់ចោលនូវការអនុគ្រោះពន្ធនាំចូល មកកាន់អ៊ឺរ៉ុបដែលជាលំហទីផ្សារនាំចេញធំជាងគេបង្អស់របស់កម្ពុជា និងទាំងទៅលើមន្ត្រីជាន់ខ្ពស់ដែលជាអ្នកទទួលខុសត្រូវនៅក្នុងគណបក្សប្រជាជនកម្ពុជា ។





LICO WIRELESS & GENERAL SERVICES

**មានលក់**
-ស៊ីមកាត -ទូរស័ព្ទដៃ&ស្រោមទូរស័ព្ទដៃ-ដោះកូដបណ្តាញ GSMរបស់ទូរស័ព្ទដៃ,កុំព្យូទ័រលើតុ និងកុំព្យូទ័រយួរដៃគ្រប់ប្រភេទ

**សេវាកម្ម**
-បង់ថ្លៃវិក្កយបត្រផ្សេងៗ
-ដោះកូដទូរស័ព្ទដៃគ្រប់ប្រភេទ

**ជួសជុល**



- កុំព្យូទ័រខូច/អាក្រង់ IPHONE ដែលបែក
- ធ្វើឲ្យកុំព្យូទ័រដើរលឿន (PC TUNE UP)
- កំចាត់មេរោគចេញពីកុំព្យូទ័រ
- បង្កើតអ៊ីម៉េល
- ការថតចម្លងទិន្នន័យទុក(DATA BACK UP)
- ពិនិត្យភាពមិនប្រក្រតីរបស់កុំព្យូទ័រដោយមិនគិតថ្លៃ (FREE COMPUTER DIAGNOSTIC)

សូមមកកាន់ហាងរបស់យើងខ្ញុំ ដែលមានអាស័យដ្ឋាន
336 WESTFORD STREET. LOWELL, MA
978-735-4100
បើកចាប់ពី: ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍ | ពីម៉ោង១០ព្រឹក -៧យប់ / ថ្ងៃអាទិត្យ បិទ



SIBORAK ERIC PONN ស៊ីបូរ៉ាក

Coco, Early & Associates/The Dutton Group



Coco, Early & Associates
The Real Estate Professionals

564 Dutton St, Lowell MA 01854
License: MA/NH
Real Estate Agent
**978-596-7935** / **sponn@cocoearly.com**

ស្មោះត្រង់ - សុចរិត - ការប្តេជ្ញាចិត្ត

លោក ស៊ីបូរ៉ាក់ អេរិក មានឆន្ទៈ ក្នុងការជួយសមាជិកនៅក្នុងសហគមន៍របស់យើងឱ្យក្លាយជាម្ចាស់ផ្ទះ។ លោកបាននាំមកនូវបទពិសោធន៍មិនរកប្រាក់ចំណេញសម្រាប់ជួយណែនាំដល់គ្រួសារជាច្រើន ដើម្បីឲ្យសម្រេចបាននូវគោលដៅភាពជាម្ចាស់គេហដ្ឋានរបស់ពួកគេមួយជំហានម្តងៗ។ លោកមានភាពស្មោះត្រង់, គួរឲ្យទុកចិត្ត និងមានការប្តេជ្ញាចិត្ត ក្នុងការផ្តល់សេវាទិញ និងលក់ផ្ទះ ដែលគួរឲ្យកោតសរសើរ។ លោក អេរិក និយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ។

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare Home Care Agency
### Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហែលស្តង់ដា

**ផលប្រយោជន៏ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- live in subsidized or public housing
- age 22 years and older
- eligible for Masshealth Standard

**Benefits you will get:**

- personal care service in your home,
- Medication Managemant
- an individual care plan developed by a registered nurse and case manager
- ongoing monitoring of needs
- 24-hour access to services

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

“នយោបាយកម្ពុជា”

# ដំណើរឆ្ពោះទៅរកលិទ្ធិផ្តាច់ការនៅកម្ពុជា“ភាគ២”

ដោយ ពិន សំខុន

យើងបាននិយាយថា "រំលាយគណបក្សសង្គ្រោះជាតិបានតែ១ថ្ងៃ គណបក្សនោះបែរជាពង្រឹងជំហ៊របានវិញដដែល" គឺនៅថ្ងៃ១៧វិច្ឆិកា ១-សេចក្តីថ្លែងការថ្កោលទោសនឹងដាក់កំហិតហ៊ុន សែន ពីសេដ្ឋវិមានអាមេរិកាំង ២-សេចក្តីសម្រេចរបស់សភាអាមេរីកាំងចាត់វិធានការផ្លូវច្បាប់ចំពោះមន្ត្រីគណបក្សប្រជាជនដែលចូលរួមឃុបឃិតជាមួយរដ្ឋបាលលោក ហ៊ុន សែន ដែលគ្រាន់តែ២វិធានការនេះសោះ គឺជាការឱ្យកម្លាំងដ៏មហិមាដល់សង្គ្រោះជាតិសម្រាប់តតាំងជាមួយលោក ហ៊ុន សែន។

ប្រជាពលរដ្ឋខ្មែរអាមេរីកាំង បានពង្រឹង ស្មារតីវិញភ្លាមជាមួយគ្នានឹងមន្ត្រីគណបក្សសង្គ្រោះជាតិដែលបានភៀសខ្លួន ពីការចាប់ចងរបស់រដ្ឋាបាលលោក ហ៊ុន សែន រួមគ្នាជាមួយលោកអតីតប្រធានសង្គ្រោះជាតិ សម រង្ស៊ី ក៏បានត្រឡប់មកចូលរួមជាមួយគណបក្សចងក្រងគ្នាឡើងវិញ ពីក្រោយសេចក្តីសម្រេចចិត្តរបស់មហាអំណាចបរទេសដែលបានផ្តេជ្ញាចិត្តគាំទ្រឱ្យមានការត្រឡប់មករកលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាវិញមក។ លោកប្រធានាធិបតី ម៉ាក្រុង នៃប្រទេសបារាំង សហាបធាននៃសនិសពាកេងប៉ារីស បានបេកាស កោះហៅហត្ថលេខីនៃប្រទេសសន្ធិសញ្ញាក្រុងប៉ារីសថ្ងៃទី២៣តុលា ១៩៩១ ស្តីពីសន្តិភាពនៅកម្ពុជាឱ្យត្រឡប់មកជួបជុំគ្នាឡើងវិញ។ រីឯសេតវិមាន ក៏ទទួលបាននូវសេចក្តីសម្រេចរបស់សភា



ទាំង២នៃអាមេរីកាំង លេខ២៧៨ ដែលនឹងបិទទិដ្ឋាការមន្ត្រីជាន់ខ្ពស់ខ្មែរ មិនឱ្យចេញចូលសហរដ្ឋអាមេរិក -បង្កកលុយដុល្លារអ្នកទាំងនោះមិនឱ្យចរាចរនៅពិភពលោក -បិទទំនាក់ទំនងមិនឱ្យនរណារកស៊ីជាមយ -ថែមទាំងបិទជំនយសេដកិច នានាជាមួយកម្ពុជាថែមទៀត។ ទាំងនេះធ្វើឡើងតែក្នុងរយៈពេល២សប្តាហ៍ បន្ទាប់ពីការរំលាយគណបក្សសង្គ្រោះជាតិមក - ហើយចំពោះព្រឹត្តិការអវិជ្ជមានចំពោះកម្ពុជាទាំងនោះ មានតែការត្រឡប់មករកភាពប្រក្រតីជាមួយគណបក្សសង្គ្រោះជាតិ ដើម្បីបន្តនិរន្តភាពនៃសន្ធិសញ្ញាក្រុងប៉ារីសតែប៉ុណ្ណោះ ដែលអាចជួយគណបក្សប្រជាជនកម្ពុជាពីការដួលរលំបានតែមិនធានាការឈ្នះឆ្នោត






លើសង្គ្រោះជាតិទេ។

លោក លឺ ឡាយស្រេង អតីតឧបនាយករដ្ឋមន្ត្រីច្រើនអាណត្តិនៃរដ្ឋាភិបាលលោក ហ៊ុន សែន



បានទស្សន៍ទាយពីអនាគតកម្ពុជា នាថ្ងៃទ១ធ្នូនេះ ថា "លោក ហ៊ុន សែន មានសត្រូវផ្ទៃក្នុងគណបក្សគាត់ ច្រើនជាងសត្រូវជាមួយសង្គ្រោះជាតិទៅទៀត ដូច្នេះលោក ហ៊ុន សែន នឹងត្រូវគ្នាគាត់បណ្តេញចេញពីបក្សមុនពេលគណបក្សប្រជាជនត្រូវរលាយដោយទទួលទណ្ឌកម្មពីបរទេស..." ចំណែកលោកឯកអគ្គរដ្ឋទូតអាមេរីកាំងប្រចាំប្រទេសកម្ពុជា វិល្លីយាំ ហៃក ក៏បានបញ្ជាក់ពីអ្វីដែលសហរដ្ឋអាមេរិកបានសម្រេចនៅសភានឹងនៅសេដ្ឋវិមាននាពេលថ្មីៗនេះ នៅក្នុងការផ្សាយរបស់"VOA" កាលពីថ្ងៃទី២៨វិច្ឆិកា ហើយលោកបានបន្តថា "ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលកម្ពុជា មិនបានបង្ហាញពីការចង់រក្សាមិត្តភាពជាមួយសហរដ្ឋអាមេរិកទេ..."។

ស្របគ្នានឹងស្ថានភាពនយោបាយកម្ពុជា ដែលចេះតែតឹងទៅមុខដោយការចាប់ចងមន្ត្រីអភ័យឯកសិទ្ធកាន់តែច្រើន ការរំលោភសិទ្ធពលរដ្ឋគ្មានរើសមុខការចាប់ប្រធានគណបក្សប្រឆាំងដ៏ធំតែមួយនឹងចុងក្រោយបង្អស់ ការរំឡាយគណបក្សប្រឆាំងដែលជាការរំលោភលើរដ្ឋធម្មនុញ្ញដោយគ្មានស្ថាប័នផ្លូវការណាមួយហ៊ានចេញមុខជំទាស់... លោក ហ៊ុន សែន បាននាំនយោបានកម្ពុជាទៅចូលក្រោមឥទ្ធិពលប្រទេសចិន ហើយថ្ងៃទី១ធ្នូនេះ ទៅចូលរួមប្រជុំក្នុងបក្សកុម្មុយនិស្តចិននៅប៉េកាំងទៀត ដោយគ្មានលាក់បាំង -ដំណើរនេះធ្វើឱ្យពលរដ្ឋខ្មែរនឹកទៅដល់អតីតកាលនៃរបបខ្មែរក្រហម ប៉ុល ពត គ្មាននរណាចង់ទៅជាមួយឡើយ។

លោក លឺ ឡាយស្រេង ដែលធ្លាប់រស់នៅមានបានលើទឹកដីសហរដ្ឋអាមេរិកនាពេលមុនធ្វើនយោបាយធ្លាប់តស៊ូប្រឆាំងរបប ហ៊ុន សែន ពីទល់ដែននឹងធ្លាប់ជាសមាជិករដ្ឋាភិបាល ហ៊ុន សែន តែមិនបានចូលរួមជាមួយចលនា"ហ៊្វុនស៊ិនប៉ិច" នាពេលនេះទេ ថែមទាំងដ្កោលទោសថែមទៀត, លោកបានផ្តល់សេចក្តីសង្ឃឹមយ៉ាងមាំថា"សូម បងប្អូនសង្ឃឹមចុះថាបន្តិចទៀតអ្វីនឹងផ្លាស់ប្តូរនៅកម្ពុជាយើង មិនយូរទេ សូមឱ្យមានការតស៊ូតែបន្តិចទៀតចុះ ហ៊ុន សែន មិនអាចនៅយូរបានទៀតទេ..." លោកមានទាំងបន្ថែមអំពាវនាវឱ្យខ្មែរទាំងក្នុងនឹងក្រៅស្រុករួបរួមគ្នាឡើងថា"សូមឱ្យសង្គ្រោះជាតិនៅឯនាយសមុទ្រ រួមគ្នាជាធ្លុងមួយ កុំឱ្យបែកបាក់គ្នា ខ្ញុំនឹងចូលទៅជួយថែមទៀត..."។

## ARTSEMERSON WELCOMES

# BANGSOKOL: A REQUIEM FOR CAMBODIA

TWO PERFORMANCES ONLY | DECEMBER 19 and 20, 2017
EMERSON PARAMOUNT CENTER'S ROBERT J. ORCHARD STAGE

Boston, MA—ArtsEmerson, Boston's leading presenter of contemporary world theatre, proudly welcomes Bangsokol: A Requiem for Cambodia—for two performances only — a collaboration by Rithy Panh and Him Sophy, survivors of the Khmer Rouge,that fuses music, film, voice and movement to address the traumas that occurred in Cambodia.Performances take place December 19 and 20, 2017 at the Emerson Paramount Center's Robert J. Orchard Stage, located at 559 Washington Street in Downtown Boston. Tickets range from $20-90, and may be purchased online at www.ArtsEmerson.org, by phone at 617.824.8400, or in person at the box office.Student, senior and group Condiscounts are available.

Bangsokol: A Requiem for Cambodia is an extraordinary new composition fusing music, film, voice and movement. It is the first major symphonic work that addresses the traumas that occurred in Cambodia in the late seventies, and is the first collaboration between the Oscar-nominated director Rithy Panh and lauded composer Him Sophy — both survivors of the Khmer Rouge and now at the forefront of Cambodia's cultural renaissance. Anchored in "bangsokol" — a ritual for the dead or soon to be deceased — the performance intertwines traditional Khmer instruments with The Metropolis Ensemble orchestra and the Taipei Philharmonic Chamber Choir. All together, they create something innately Cambodian but relatable to audiences everywhere.

Bangsokol is an act of cultural renewal, aiming to return the arts to their place at the heart of Cambodian society. While the world continues to witness new genocides, wars and destruction, Bangsokol urges us to express our scars from the past in order to forge a new path forward. Click here to view the Bangsokol: Requiem for Cambodia **Continued to Page 20**




# បង់ថ្លៃប្ញូកផ្សំ $0

ណាត់ជួបវេជ្ជបណ្ឌិត $0 ការមើលថែធ្មេញ $0 សេវាចក្ខុវិញ្ញាណ $0

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth រួមបញ្ចូលទាំងការធានាលើថ្នាំតាមវេជ្ជបញ្ជា Part D ឬកផ្សំនឹងអត្ថប្រយោជន៍ច្រើនទៀតដូចជា៖

- ប័ណ្ណ OTC សម្រាប់ទិញថ្នាំ និងផលិតផលិតផលទាក់ទងនឹងសុខភាពជាក់លាក់ដែលមិនចាំបាច់វេជ្ជបញ្ជា *(រហូតដល់ $300 ក្នុងមួយឆ្នាំ ឬ $75 ក្នុងមួយត្រីមាស)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំគិលានុបដ្ឋាកដែលសម្របសម្រួលការមើលថែទាំរបស់អ្នកដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក។

**ទាំងអស់ក្នុងផែនការងាយស្រួលតែមួយពី Senior Whole Health។**



ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare Part A និង/ឬ Part B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
(លេខឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងបើកពីម៉ោង 8 ព្រឹកដល់ 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលគ្រប់ដណ្តប់ និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។*
*ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY/TDD: 711).*
*ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY/TDD: 711).*

សុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា (HMO SNP) និងសុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS។ ការចុះឈ្មោះធ្វើឡើងតាមការស្ម័គ្រចិត្ត និងអាស្រ័យលើការបន្តកិច្ចសន្យាពល់ឆ្នាំ។ ព័ត៌មាននេះពុំមែនជាការពិពណ៌នាពេញលេញនៃអត្ថប្រយោជន៍ឡើយ។ ទាក់ទងផែនការនេះសម្រាប់ព័ត៌មានបន្ថែម។ អាចនឹងមានការដាក់កម្រិត ការបង់ថ្លៃប្ញូកផ្សំ និងការកំហិត។ អត្ថប្រយោជន៍អាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ សហចំណាយអាចប្រែប្រួលអាស្រ័យលើកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទំនាក់ទំនងទៅផែនការសម្រាប់ព័ត៌មានលម្អិតបន្ថែម។ ផែនការនេះអាចប្រើបានសម្រាប់អ្នកអាយុ 65 ឆ្នាំឡើងទៅ ដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare។ H2224_2016_138kh Accepted 11/25/2016


ហាងកែសម្ផស្ស
May May
BEAUTY
20 Cambridge Street
Burlington, MA 01803
(781)-272-1389
ការដាក់លក់ផលិតផលសម្រាប់អបអរសាទរគំរប់ខួប ១០ ឆ្នាំ
បញ្ចុះតម្លៃពី ១៥ % - ២០% គ្រាប់ផលិតផលគ្រឿងសំអាងទាំងអស់
ទទួលការព្យាបាលម្តងក្នុងចំណោមសេវាព្យាបាលទាំង ១០ រឺ ទាំង ១២
របស់ហាងយើងខ្ញុំ នឹងទទួលបានការព្យាបាល ២ ដងបន្ថែមដោយមិនគិតថ្លៃ
សេវាព្យាបាលម្តងបញ្ចុះតម្លៃ៣០% ( ព្យាបាលទៅលើការបករោម
តំរឹមរោម ចិញ្ចើម
ផាត់ពណ៌លើគ្របកភ្នែក
តរោមចិញ្ចើម
គូរចិញ្ចើម/រោមភ្នែក
ពត់រោមភ្នែក
បំបាត់ស្នាមអុជខ្មៅ (អាចម៍រុយ)
បំបាត់ស្នាមជាំដោយសារកំដៅថ្ងៃ និង បំបាត់សាច់ដុះនៅលើស្បែក )
G.M. COLLIN
ការផ្តល់ជូនពិសេសនេះ ផុតកំណត់នៅថ្ងៃទី ២៨ ខែកុម្ភះ ឆ្នាំ ២០១៨


ស្នាមញញឹមកាន់តែប្រសើរ
ជាមួយពេទ្យធ្មេញYoung Dentistry
YOUNG K. SON D.M.D.
Family Dentistry
674
* ការបណ្តុះដាំធ្មេញ (Bonding)
* ស្រោបធ្មេញ&តំណភ្ជាប់ធ្មេញពីរ
* ការដាំបង្គោលធ្មេញ
* ជំនាញខាងសម្អាតធ្មេញ
* ធ្វើឲ្យធ្មេញសស្អាត
* ធ្វើធ្មេញដោះដាក់
* បិតប៉ះធ្មេញ
* ព្យាបាលរោគអញ្ចាញធ្មេញ
ធ្វើការជួសជុលធ្មេញដែលបែក និងប្រេះស្រាំតូច និងធំ និងកែសំរួលទំរងធ្មេញ
ដកធ្មេញគ្រប់ប្រភេទ
យុវវ័យ និងកុមារ
ទទួលយកក្រេឌីតកាត (Credit Cards)&ប័ណ្ណឥណទាន(Care Credit)
www.YoungDentistryPC.com
674 Rogers Street. Lowell, MA 01852 / 978-459-0594


CAMBRIDGE
A DIVISION OF PACE INDUSTRIES
យើងខ្ញុំផ្តល់ឲ្យនូវអាជីប, មិនមែនការងារទេ!
អតិថិជនរបស់យើងខ្ញុំ មានដូចជា Harley Davidson, Military, Starbucks និងមានជាច្រើនផ្សេងទៀត
ថ្មីៗកំពុងជ្រើសរើស
អ្នកកាន់ម៉ាស៊ីន, អ្នកតំឡើង និងអ្នកជួសជុលម៉ាស៊ីន
មិនត្រូវឲ្យមានបទពិសោធន៍! កំពុងស្វែងរកអ្នកបំពេញការងារគ្រប់កម្រិតសម្រាប់វេន ១ និង ២។
នៅ Cambridge Division ដែលជាផ្នែកមួយរបស់ក្រុមហ៊ុន Pace Industries, យើងរីកចំរើនទាំងអស់គ្នា។ យើងបង្កើនទេពកោសល្យ។ យើងផ្តល់ឲ្យលោកអ្នកនូវឱកាសក្នុងការអភិវឌ្ឍន៍អាជីពដោយផ្អែកលើភាពខ្លាំង និងសក្តានុពលរបស់លោកអ្នក។ ក្រុមហ៊ុន Pace គឺជាទីកន្លែងដែលផ្តល់នូវគោលដៅនៃអាជីពមួយសម្រាប់អ្នកដែលមានទេពកោសល្យ, មានចំណាប់អារម្មណ៍ខ្លាំង, និងមានការចូលរួម ដើម្បីស្វែងរកនូវការច្នៃប្រឌិត, ការរីកចំរើន និងឱកាសដែលមានតែយើងជាអ្នកផ្តល់ឲ្យ។
យើងខ្ញុំផ្តល់នូវអត្ថប្រយោជន៍ដូចជា ការធានារ៉ាប់រងជីវិត, ធានារ៉ាប់រងពិការភាពរយៈពេលខ្លី, វិស្សមកាល, ការឈប់សម្រាក១០ថ្ងៃក្នុងមួយឆ្នាំដោយបានទទួលប្រាក់ឈ្នួល, ការឈប់សម្រាប់ទទួលបានប្រាក់ឈ្នួល ដោយកាត់ពីវិស្សមកាល និងការឈប់ពេលមានជំងឺ, ការធានាលើសុខភាព, ធ្មេញ និងភ្នែក, ការបង់រំលះថ្លៃសិក្សា, និងមានច្រើនផ្សេងទៀត។


FedEx Ground
Think Fast.
Think FedEx Ground.
Interested in a fast-paced job with career advancement opportunities? Join the FedEx Ground team as a package handler.
Package Handlers
$14.25 to start
Compensation
• Multiple pay increases within the first six months of employment
• Tuition reimbursement program
• Career advancement opportunities
• Weekly paycheck/direct deposit
Qualifications
• Must be at least 18 years of age
• Must be able to load, unload and sort packages, as well as perform other related duties
Full-time and flexible schedules available in some locations.
For more information, please visit
GroundWarehouseJobs.fedex.com
FedEx Ground is an equal opportunity/affirmative action employer (Minorities/Females/Disability/Veterans) committed to a diverse workforce.

# ក្រុមហ៊ុន ម៉េសត្រូ ខននិចសិន ហេលស៊ីស ស្ទឹមនៅឡូវែលត្រូវពិន័យសំណងចំនួនជាង១ លានដុល្លារចំពោះការបំពានច្បាប់ប្រាក់ឈ្នួល

ប៉ូសស្តុន - ក្រុមហ៊ុន ម៉េសត្រូ ខននិចសិន ហេលស៊ីសស្ទឹម មានទីតាំងនៅឡូវែន និងជាក្រុមហ៊ុនដែលផ្តល់សេវាកម្មសុខភាពតាមផ្ទះត្រូវបានទទួលរងការផាកពិន័យចំនួនទឹកប្រាក់ជាង១លានដុល្លារ ដោយសារកិបកេញមិនបង់ប្រាក់ម៉ោងបន្ថែមរបស់បុគ្គលិកដែលមានរយៈពេលជិតបីឆ្នាំ មកហើយ។

បើយោងតាមការចេញផ្សាយរបស់អគ្គមេធាវីរដ្ឋម៉ាសាជូសេតកាលពីថ្ងៃអង្គារ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ បានឱ្យដឹងថា ក្រុមហ៊ុនម៉េសត្រូ




នឹងត្រូវបង់ប្រាក់ច្រើនជាង១លាន់ដុល្លារ ជាការសងជំងឺចិត្ត និងការដាក់ទណ្ឌកម្ម ចំពោះការមិនបានបង់ប្រាក់ដែលបុគ្គលិករបស់ខ្លួនធ្វើការងារលើសពី៤0ម៉ោងក្នុងមួយសប្តាហ៍។

ប្រភពដដែលបានបញ្ជាក់ថា ក្រុមហ៊ុននេះមិនបានបង់ប្រាក់បន្ថែមម៉ោងចំនួន១.៥គុណនឹងអាត្រាប្រាក់ម៉ោងធម្មតាសម្រាប់ម៉ោងនិមួយៗដែលលើស៤0 ម៉ោងនោះទេ។ ហេតុដូច្នេះហើយតាមច្បាប់ ក្រុមហ៊ុនម៉េសត្រូ ត្រូវបានការិយាល័យតម្លាភាពការងារតំរូវឱ្យធ្វើការប្រមូលព័ត៌មានបុគ្គលិកដែលធ្វើការងារបន្ថែមម៉ោងក្នុងមួយថ្ងៃៗ និងមួយសប្តាហ៍ៗ ដើម្បីធ្វើការទូតទាត់សងជំងឺចិត្ត។

តែលោក ចច កីអនគេរា ដែលជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនម៉េសត្រូបានឱ្យដឹងថា ក្រុមហ៊ុនមិនបានរក្សាការកត់ត្រាការចំណាយបងប្រាក់បៀវត្សរ៍បានត្រឹមត្រូវនោះទេក្នុងចន្លះពីខែមិថុនាឆ្នាំ២០១៣ដល់ខែតុលាឆ្នាំ២០១៦។ បើតាមការប៉ាន់ប្រមាណបុគ្គលិកនឹងទទួលបានការទូទាត់សងជំងឺចិត្តជាមធ្យមចំនួន១,៤៥0ដុល្លារពីក្រុមហ៊ុនម៉េសត្រូនេះ។

គួបញ្ជាក់ថា ក្រុមហ៊ុនសត្រូ ខននិចសិន ហូមហេលស៊ីសស្ទឹម មានបុគ្គលិកទាំងអស់ចំនួនជាង៦00នាក់ ដោយនៅក្នុងនោះ បុគ្គលិកជាង១៣0 នាក់ គឺជាអ្នកមកពីនៅឡូវែល។

ក្នុងសេចក្តីប្រកាសព័ត៌មានដដែរបានដកស្រង់សំដីរបស់អគ្គមេធាវីលោក ម៉ូរ៉ា ហេលីថា "បុគ្គលោកទាំងនេះផ្តល់សេវាថែទាំសុខភាពសំខាន់ៗដល់មនុស្សចាស់និងអ្នកដទៃផ្សេងទៀត ហើយពួកគេសមនឹងទទួលបានការបង់ប្រាក់ដោយត្រឹមត្រូវមិនសត្រូវបោកប្រាស់ដោយនិយោជករបស់ពួកគេទេ"។

យោងតាមច្បាប់កាងារនៅម៉ាសាជូសេតប្រាក់ឈ្នួលអប្បបរមាដែលបានចូលជាធមានកាលពីខែ មករា ឆ្នាំ២០១៧ សម្រាប់អ្នកបំរើការងារភាគច្រើនបានកើនឡើងដល់១១ដុល្លារ ក្នុងមួយម៉ោង និង៨ដុល្លារ ក្នុងមួយម៉ោងសម្រាប់អ្នកបំរើការងារនៅក្នុងវិស័យកសិកម្ម។ សម្រាប់ការងារលើសម៉ោងអ្នកបំរើការងារភាគច្រើនដែលធ្វើការលើសពី៤0ម៉ោងក្នុងមួយសប្តាហ៍ ត្រូវបងប្រាក់បន្ថែមសម្រាប់កិច្ចការលើសម៉ោងនោះ ដោយគិតអាត្រាយោងហោចណាស់ ១.៥ គុណនឹងអាត្រាប្រាក់ម៉ោងធម្មតាសម្រាប់ម៉ោងនិមួយៗដែលលើស៤0ម៉ោងនោះ។

ច្បាប់ក៏បានអនុញ្ញាតឱ្យអ្នកបំរើការងារប្រើប្រាស់ការឈប់សម្រាក់ពេលមានជំងឺ(Earned sick time) ប្រសិនបើអ្នកបំរើការងារនោះ (រឺកូន, ប្តីរឺប្រពន្ធ, ឪពុកម្តាយ រឺឪពុកម្តាយរបស់ ប្តីរឺប្រពន្ធ) មានជំងឺ, មានគគ្រោះថ្នាក់របួស រឺមានការណាត់ជួបជាមួយគ្រូពេទ្យជាទៀងទាត់ណាមួយនោះ។

ប្រសិនបើសិទ្ធរបស់លោកអ្នកត្រូវបានបំពានក្នុងប្រការណាមួយនៅកន្លែងការងារ សូមទំនាក់ទំនងទៅកាន់ការិយាល័យតម្លាភាពការងារ (Fair Labor Division)តាមរយៈ Hotline (617) 727-3465។ លោកកអ្នកក៏អាចចូលទៅកាន់វិបសាយ www.mass.gov/ago/fairlabor សម្រាប់ព័ត៌មានទាក់ទងនឹងច្បាប់ប្រាក់ឈ្នួល និងប្រាក់ម៉ោងការងារសម្រាប់រដ្ឋម៉ាសាជូសេត។

# HOME HEALTH COMPANYAGREES TO PAY MORE THAN $1 MILLION FOR NOT PROVIDING OVERTIME WAGES TO AIDES More Than 600 Home Health Workers Will Receive Their Unpaid Wages

*-by KhmerPost USA and Translation by Sokharatha Koy*

BOSTON – A home health care company has agreed to pay more than $1 million in restitution and penalties after failing to pay overtime to more than 600 home health aides and failing to keep accurate payroll records, Attorney General Maura Healey announced today.



Attorney General Maura Healey

In a settlement agreement with the AG's Office, Lawrence-based Maestro-Connections Home Health Systems, LLC (Maestro) and its sole manager George Kiongera have agreed to pay $1,007,717 in restitution and penalties for failing to pay employees overtime and failing to keep true and accurate payroll records between June 2013 and October 2016.

"These workers provide critical health care services to seniors and others and they deserve to be paid properly, not cheated by their employer," said AG Healey. "With this settlement, hundreds of home health aides will now be paid the money they are owed."

The AG's Fair Labor Division began an investigation in 2016 after receiving an anonymous tip.

The investigation found that Maestro, established to provide home health services, including skilled nursing and home health aide visits, failed to pay its home health aides time and one-half when they worked over 40 hours in a week. The state's overtime law requires employers to pay qualifying employees time and one half their regular rate of pay for all hours worked over 40 in a work week.

Employers are also required by state law to keep true and accurate records which contain information including the names of each of their employees and the number of hours they work each day and each week, which Maestro did not do.

On average, workers will receive $1,450 in restitution pursuant to the settlement agreement. The company has since changed its practices to ensure that all eligible workers are paid overtime and accurate records are kept.

AG Healey's Fair Labor Division is responsible for enforcing state laws regulating the payment of wages, including prevailing wage, minimum wage and overtime laws.

Workers who believe that their rights have been violated in their workplace can call the office's Fair Labor Hotline at (617) 727-3465. Workers may also file a complaint and find information about the state's wage and hour laws in multiple languages at www.mass.gov/ago/fairlabor.

This matter was handled by Assistant Attorney General Anita V. Maietta and Investigator Leah Lucier, both of AG Healey's Fair Labor Division.

# សមាជិកថ្មីនៃសហគមន៍ខ្មែរនៅឡូវែល

ខ្មែរផុសស.រ.អា.

ក្រុងឡូវែលយើង ទើបនឹងទទួលសមាជិកថ្មី៤គ្រួសារ ដែលទើបនឹងមកដល់ពីកម្ពុជា អ្នកទាំងនោះគឺ១-គ្រួសារសេដ្ឋា ផេង មានប្តីប្រពន្ធនឹងកូនប្រុស២ស្រី២ តែកូនស្រ១មួយមិនបានមកទេដោយហួសអាយុ, ២-គ្រួសារឈ្មោះ ឈួន ប្រុស មានប្តីប្រពន្ធនឹងកូន២នាក់ប្រុស១ស្រី១ ៣-គ្រួសារឈ្មោះ ឈុង សូភី មានប្តីប្រពន្ធនឹងកូន៤នាក់ស្រី៣ប្រុស១ ៤-គ្រួសារឈ្មោះ ប៊ុន សំបូរ មានប្តីប្រពន្ធនឹងកូន៣នាក់ស្រី២ប្រុស១។ មកដល់ឡូវែលគ្រួសារទាំង៤ បានត្រូវទទួលស្វាគមន៍ពី"សមាគមមូលនិធិឃុំសង្កាត់គំរូកម្ពុជា" ដែលជាសមាគមមិនរកប្រាក់ចំណេញ 501C3 ចុះឈ្មោះនៅរដ្ឋម៉ាសាឈូសិត បានណែនាំឱ្យគ្រួសារទាំងនោះ មានការងាយស្រួលនឹងស្នាក់អាស្រ័យជាមនុស្សចំណូលថ្មីនៅប្រទេសថ្មី ទីកន្លែងក៏ថ្មី រីឯវប្បធម៌ក៏មិនដូចគ្នាថែមទៀត។

ក្រុងឡូវែលបានផ្តល់ជូនអ្នកចំណូលថ្មីទាំងនោះ នូវដំបន់មួយដែលមានសហគមន៍ខ្មែរច្រើនមករស់នៅតាំងតែពីជាង៣០ឆ្នាំមកហើយ ម្ល៉ោះហើយតំបន់នេះបានប្តូរមុខមាត់ទៅតាមជនជាតិខ្មែរជំនាន់មុនៗ បានច្រើនក្រៃលហើយដែរ ដែលមនុស្សចំណូលថ្មីក្រោយៗមិនប្រទះភាពចំឡែកច្រើនពេកទេ។



គ្រួសារទាំងបួននោះ បានឱ្យដឹងថា "ពួកខ្លួនធ្លាប់ធ្វើការជាបុគ្គលិកសន្តិសុខឱ្យស្ថានទូតអាមេរិកាំងចំនួន២០ឆ្នាំម្នាក់ៗរួចមកហើយ នៅចុងបញ្ចប់ក៏បានទទួលអនុគ្រោះដោយការចាប់ឆ្នោតទិដ្ឋាការស្នាក់អាស្រ័យអចិន្ត្រៃយ៍អាចនាំគ្រួសារមកអាមេរិកនេះបាន"។ នៅពេលខ្មែរផុសសួរលោក សេដ្ឋា ផេង ថា"ហេតុអ្វីក៏ជ្រើសយកទីតាំងសម្រាប់រស់នៅឡូវែល?" ផេងតបវិញថា "ខ្ញុំបានជ្រើសយកកាលីហ្វ័ញ៉ាពេលរៀបចេញមក ប៉ុន្តែមានអ្នកមកដល់មុនខ្ញុំ៣-៤ខែ បានប្រាប់ខ្ញុំថា គ្មានការខកចិត្តច្រើន ពេលមកដល់"កាលី" គេក៏ជន្លៀសខ្លួនចេញមកឡូវែលវិញដែលអ្នកមកដល់មុនៗគេមានការពេញចិត្តច្រើននឹងឡូវែល ដូច្នេះខ្ញុំក៏ប្តូរទីតាំងសំដៅមកឡូវែលក្រោយគេវិញ ដែលជាហេតុធ្វើឱ្យលិខិតស្នាមខ្ញុំ មានការយឺតយ៉ាវបន្តិច..." លោក ឈួន ប្រុស ដែលជាអ្នកមានបទពិសោធន៍ទៅឯ "តិចសាស់"នោះ បានប្រាប់យើងថា "ខ្លួនបានទៅដល់ទីនោះ ក៏បានការធ្វើភ្លាមតែការរកលុយបានដោយធ្វើ"នុំដូណាត់" មិនបានជួយដល់ភាពស្របច្បាប់របស់ខ្លួននឹងគ្រួសារទេ ពីព្រោះពុំមានពេលសម្រាប់រត់ការនឹងពុំបានការណែនាំអ្វីទាល់តែសោះ, អ្នកដែលគេមកដល់អាមេរិកពេលជាមួយគ្នាមកនៅឡូវែល គេបានសសើរពីសំណាងរបស់គេដែលបានជួបក្រុមដែលជួយណែនាំ ជីវភាពពួកគេបានប្រសើរ ឮដូច្នោះហើយ ក៏នាំគ្រួសារមករស់នៅឡូវែលនេះវិញ ឥឡូវខ្លួនបានរីករាយនឹងនៅឡូវែលនេះច្រើនណាស់ហើយ..."។ក្រុម"សមាគមមូលនិធិឃុំសង្កាត់គំរូកម្ពុជា"ដែលមានអ្នករស់នៅទីនេះយូរឆ្នាំ បានណែរនាំគ្រួសារថ្មីថ្មោង ឱ្យទៅជួបសមាគមខ្មែរសមាគមអាមេរិកាំងអង្គការជំនួយជាច្រើន ដែលនៅក្នុងក្រុង ក៏រកឃើញជំនួយគ្រប់បែបយ៉ាងមានទាំងកាងារធ្វើមានសំលៀកបំពាក់ត្រឹមត្រូវសម្រាប់ខែរងារកូនចៅក៏បានទៅរៀនសូត្រគ្រប់គ្នា ...រាល់ពេលព្រឹកអ្នកជួយក៏ស្ម័គ្រយកចិត្តពេលវេលាជួយ បន្ទាប់ពីស្រស់ស្រូបហូបគុយទាវពេលព្រឹកជុំគ្នានៅហាង"ភ្នំពេញផ្លូវវៃសហ្វត" ទាំងអស់គ្នាក៏បានទទួលលទ្ធផលគាប់ចិត្តហើយរីករាយគ្រប់ៗគ្នា។

បងប្អូនខ្មែរជាច្រើន បានទទួលអនុគ្រោះដោយទិដ្ឋាការរបៀបអ្នកទាំង៤គ្រួសារនេះ ដោយសហរដ្ឋអាមេរិកមានបញ្ចេញការចាប់ឆ្នោតទិដ្ឋាការប្រមាណ៩០០នាក់ក្នុង១ឆ្នាំៗ។







# "រ៉ូដអាយឡិនជ្រើសរើសកងប៉ូលីសសម្រាប់រដ្ឋ

ខាងក្រោមនេះជាការផ្សព្វផ្សាយរបស់រដ្ឋ"រ៉ូដអាយឡិន" ដើម្បីរកបេក្ខជនអាយុពី១៨-៣៥ឆ្នាំ ប្រឡងចូលធ្វើជាកងកម្លាំងប៉ូលីសរដ្ឋ សម្រាប់អ្នកដែលមានកំរឹតសិក្សាហាយស្កូល"Hight school Doploma or GED" - បេក្ខជននឹងចូលទៅហាត់ហ្វឹកហ្វឺននៅមជ្ឈមណ្ឌលប៉ូលីសរដ្ឋរ៉ូដអាយ ឡិន នឹង-មានប្រាក់បៀវត្សរ៍ពី៦០,៦៩៧.០០ដល់ ៧៤,០០៤.០០ក្នុងមួយឆ្នាំ ។ សូមអានសេចក្តីប្រកាស លំអិតរបស់ក្រសួងប៉ូលីស"រ៉ូដអាយឡិន"ដូចតទៅៈ



| | |
|---|---|
| Job Title: | TROOPER |
| Department: | DEPARTMENT OF PUBLIC SAFETY |
| Division: | State Police |
| Opening Date/Time: | Wed. 09/27/17 12:00 AM Eastern Time |
| Closing Date/Time: | Wed. 12/27/17 11:59 PM Eastern Time |
| Salary: | $27.79 - $33.88 Hourly<br>$60,697.00 - $74,004.00 Annually |
| Pay Grade: | 80A |
